# អាទិត្យទី១៦នៃរដូវធម្មតា
# ព្រះសហគមន៍សន្ដីម៉ារីញញឹម ចំការទៀង
# ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១
# “សុខសន្តិភាព ដែលមកពីព្រះយេស៊ូគ្រីស្តផ្ទាល់”

បងប្អូនជាទីស្រឡាញ់

ថ្ងៃនេះ យើងបានឃើញរបៀបព្រះយេស៊ូជាមួយក្រុមគ្រីស្តទូត ក្រុមគ្រីស្តបានទៅប្រកាសដំណឹងល្អហើយវិលត្រលប់មកវិញ ព្រះយេស៊ូបានណែនាំឱ្យក្រុមគ្រីស្តទូតរៀបរាប់ទូលព្រះអង្គ អំពីកិច្ចការទាំងប៉ុន្មានដែលគេបានធ្វើ និងសេចក្តីទាំងអស់ដែលគេបានបង្រៀន។ តាមពិត ព្រះយេស៊ូបានប្រមូលក្រុមគ្រីស្តទូតសារជាថ្មីដើម្បីធ្វើរបាយការណ៍អំពីកិច្ចការ នៅក្នុងមួយខែកន្លងមក**បានធ្វើអ្វីខ្លះ? បានទៅដល់ភូមិណាខ្លះ? បានទៅប្រកាសដំណឹងល្អរបៀប? បានទៅបង្រៀនមហាជនរបៀបណា? បានជួបបញ្ហាអ្វីខ្លះ? តើមានអ្វីដែលយើងត្រូវតែកែដើម្បីប្រកាសដំណឹងល្អ?**

ថ្មីៗនេះ ខ្ញុំបានជួបជាមួយប្រធានការិយាល័យទាំងអស់នៅក្នុងភូមិភាគភ្នំពេញ ដើម្បីធ្វើរបាយការណ៍ដែរ។ ខ្ញុំបាននិយាយទៅប្រធានការិយាល័យនីមួយៗ ដែលយើងមាននៅក្នុងភូមិភាគភ្នំពេញថា “**របាយការណ៍ដែលយើងបង្ហាញថ្ងៃនេះ មិនមែនជារបាយការណ៍ដែលយើងរៀបចំកន្លះម៉ោងមុនប្រជុំ ប៉ុន្តែ របាយការណ៍ដែលចេញពីស្នាដៃរបស់យើងពោរពេញដោយអត្ថន័យ ពោរពេញដោយតម្លៃ**”។ ដោយសារពេញមួយឆ្នាំកន្លងមក យើងបានយកចិត្តទុកដាក់លើការងាររបស់យើង។ ជួនកាលយើងលឺថាសព្វថ្ងៃ មានកន្លែងខ្លះនៅតាមសាលារៀនពិបាកប្រមូលសិស្ស ពិបាកបង្រៀនពីចម្ងាយត្រឹមត្រូវ ប៉ុន្តែប្រចាំខែរបាយការណ៍បានចេញយ៉ាងពេញលក្ខណៈ។ មានពិន្ទុគ្រប់ មានវត្តមានសិស្សគ្រប់ ជួនកាលណែនាំឱ្យយើងឆ្ងល់ដែរ។ ប៉ុន្តែ អ្វីដែលសំខាន់សម្រាប់យើង យើងដឹងថាអ្វីដែលយើងបានធ្វើយើងធ្វើរួចហើយ អ្វីដែលយើងមិនបានធ្វើគឺយើងមិនបានធ្វើ។ ហេតុនេះហើយ នៅពេលយើងបង្ហាញរបាយការណ៍ណាមួយ របាយការណ៍នេះចេញអំពីការងាររបស់យើងពីមួយថ្ងៃទៅមួយថ្ងៃ និងណែនាំឱ្យយើងមានកម្លាំងកាយកម្លាំងចិត្តដើម្បីទៅ

មុខ ដោយសាររបាយការណ៍ជារបៀបដែលយើងវាយតម្លៃ។ ព្រះយេស៊ូបានណែនាំឱ្យគេវាយតម្លៃ ដើម្បីមើលឃើញអ្វីដែលល្អ អ្វីដែលស្មើ អ្វីដែលខ្វះ ដើម្បីទៅមុខតទៅទៀត។ សម្រាប់យើងនៅក្នុងព្រះសហគមន៍ក៏ដូចគ្នាដែរ នៅតាមកន្លែងធ្វើការរបស់យើងម្នាក់ៗក៏ដូចគ្នាដែរ យើងវាយតម្លៃមើលអ្វីដែលខ្វះ អ្វីដែលល្អ អ្វីដែលស្មើ អ្វីដែលត្រូវការកែ នេះជាកម្លាំងមួយយ៉ាងពិសេស។

ប្រសិនបើ យើងមើលរបៀបរបស់ព្រះយេស៊ូថែមទៀត ព្រះយេស៊ូដូចជាមានព្រះហឫទ័យអាណិតមេត្តាដល់ក្រុមគ្រីស្តទូត។ ដោយសារ បានយកចិត្តទុកដាក់ធ្វើការប្រកាសដំណឹងល្អអស់ពីសមត្ថភាព ព្រះយេស៊ូចង់ឱ្យគេទៅកន្លែងស្ងាត់ដើម្បីសម្រាកបន្តិច។ ប៉ុន្តែ ជាមួយមហាជនគេធ្វើមិនបានទេ ដោយសារមហាជនមានសេចក្តីត្រូវការច្រើនណាស់។ ដូច្នេះ ពេលមហាជនបានឃើញព្រះយេស៊ូនិងក្រុមសាវ័កជិះទូកទៅមុខបន្តិច គេនាំគ្នារត់ដើម្បីទៅដល់មុន។ នៅពេលព្រះយេស៊ូនិងក្រុមសាវ័កទៅដល់មានមហាជនអង្គុយ ដើម្បីរង់ចាំស្តាប់ការបង្រៀនថែមទៀត ដូច្នេះគ្មានពេលដើម្បីសម្រាក។ ប៉ុន្តែ យើងដឹងថាព្រះអង្គមានព្រះហឫទ័យអាណិតអាសូរទាំងក្រុមគ្រីស្តទូត ទាំងមហាជន ដោយយល់ថាមហាជនដូចជាខ្វះគ្រូគង្វាលដើម្បីថែទាំ។ ដូច្នេះ ព្រះយេស៊ូបន្តបង្រៀន លើកទឹកចិត្ត ព្យាបាល ធ្វើដំណើរជាមួយគេ។

បងប្អូនជាទីស្រឡាញ់ សប្តាហ៍មុនខ្ញុំបានអញ្ជើញឱ្យយើងទាំងអស់គ្នាជាគ្រីស្តបរិស័ទ ជាបូជាចារ្យ ជាបងប្រុសបងស្រី ជាអ្នកស្ម័គ្រចិត្ត ជាអង្គការកាតូលិក ជាគ្រូគង្វាលនៅក្នុងព្រះសហគមន៍ឱ្យគិតពិចារណាអំពី៤ចំណុចគឺ ជីវិតខាងផ្លូវវិញ្ញាណ អប់រំជំនឿនិងអប់រំយុវជនយុវនារី អប់រំសិក្សានៅក្នុងសាលាកាតូលិកយើង និងធម៌មេត្តាករុណា។ ដោយសារទោះមានឬគ្មានកូវីដ-១៩ យើងត្រូវតែបន្តប្រកាសដំណឹងល្អ ជាតួនាទីដែលព្រះយេស៊ូប្រទានឱ្យក្រុមគ្រីស្តទូតពីដើម ជាតួនាទីដែលព្រះយេស៊ូប្រទានឱ្យយើងសព្វថ្ងៃ។ ប្រកាសដំណឹងល្អ ផ្សព្វផ្សាយអំពីដំណឹងល្អ ព្រះយេស៊ូកំពុងយាងមក ព្រះយេស៊ូជាព្រះមហាក្សត្រនៃសុខសន្តិភាព ដូចយើងបានស្តាប់នៅក្នុងអត្ថបទទី២។ សម្រាប់យើងជាគ្រីស្តបរិស័ទ យើងធ្វើដូចម្តេចដើម្បីផ្សាយដំណឹងល្អ ដើម្បីឱ្យយើងចម្លងពីម្នាក់ទៅម្នាក់ទៀតអំពីអំណរសប្បាយ និងសេចក្តីស្រឡាញ់ដែលយើងបានទទួលពីព្រះជាម្ចាស់។ សព្វថ្ងៃ យើងត្រូវការពារថែរក្សាខ្លួនកុំឱ្យយើងឆ្លងជំងឺកូវីដ-១៩មែន ប៉ុន្តែយើងត្រូវតែយកចិត្តទុកដាក់ដើម្បីចម្លងអំពីអំណរសប្បាយដែលយើងមាន។ ដោយសារ ព្រះបន្ទូលរបស់ព្រះយេស៊ូដែលដឹកនាំជីវិតរបស់យើង ដែលណែនាំឱ្យយើងបំផ្លាញជញ្ជាំងដែលយើងបង្កើតរវាងមនុស្សនឹងមនុស្ស រវាងជាតិសាសន៍មួយនឹងជាតិសាសន៍មួយទៀត។

សព្វថ្ងៃ យើងកំពុងភ័យម្តងទៀតព្រោះថាប៉ុន្មានថ្ងៃមុនយើងបានស្តាប់ក្រសួងសុខាភិបាល បានប្រកាសថា កូវីដ-១៩ប្រភេទថ្មីកំពុងចូលដល់ទឹកដីខ្មែរ។ វាបានចូលដល់ប៉ុន្មានប្រទេសហើយដែលណែនាំឱ្យយើងឆ្លងភ្លាម (១៥វិនាទីអាចចម្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត)។ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ប្រទេសកម្ពុជាយើងបានចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋបានច្រើនហើយស្របពេលដែលប្រទេសជិតខាងបានតែមួយចំនួនតូច។ ដូច្នេះ ប្រទេសកម្ពុជាយើងបានចាក់វ៉ាក់សាំងបន្ទាន់ ដើម្បីការពារថែរក្សាជំងឺកូវីដ-១៩កុំឱ្យចូលក្នុងខ្លួនប្រជាពលរដ្ឋម្នាក់ៗ។ សម្រាប់យើងជាគ្រីស្តបរិស័ទ យើងមិនអាចចាក់វ៉ាក់សាំងដើម្បីឱ្យយើងស្ពឹកនៅក្នុងការប្រកាសដំណឹងល្អ។ ផ្ទុយទៅវិញ យើងមានកម្លាំងដែលមកពីព្រះជាម្ចាស់ ដែលមកពីព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីពោរពេញដោយសេចក្តីស្រឡាញ់ ពោរពេញដោយជំនឿ ពោរពេញដោយសេចក្តីសង្ឃឹម។ ឱ្យយើងផ្សាយដំណឹងល្អពីមនុស្សម្នាក់ទៅមនុស្សម្នាក់ ឱ្យដំណឹងល្អនេះឆ្លងឆាប់ៗ។

យើងបានស្តាប់ "**ព្រះយេស៊ូនេះហើយ ដែលជាសន្តិភាពរបស់យើង បានរំលំជញ្ជាំងដែលធ្វើឱ្យសាសន៍ដទៃនៅដាច់ពីគ្នា ហើយជាបញ្ចមិត្តនឹងគ្នា ផ្ទុយទៅវិញព្រះយេស៊ូគ្រីស្តណែនាំឱ្យមនុស្សយើង ទៅជាមិត្តសំលាញ់នៅក្នុងអង្គព្រះគ្រីស្ត ទៅជារូបកាយតែមួយនៅក្នុងអង្គព្រះគ្រីស្ត ព្រះអង្គបានយាងមកដើម្បីនាំដំណឹងល្អអំពីសន្តិភាព មកឱ្យបងប្អូនដែលនៅឆ្ងាយ និងនាំសន្តិភាពមកឱ្យអស់អ្នកដែលនៅជិតដែរ**" នេះជាដំណឹងល្អដែលយើងបានទទួលថ្ងៃនេះ។ ប៉ុន្តែ បើយើងមើលក្នុងអត្ថបទទី១ ថ្ងៃនេះព្រះជាម្ចាស់ដូចជាបានណែនាំឱ្យយើងភ្ញាក់ស្មារតី យើងជាលោកអភិបាល យើងជាគ្រូគង្វាល យើងជាគ្រូអប់រំជំនឿ យើងជាមេក្រុមយុវជន យើងជាអ្នកដឹកនាំនៅក្នុងសាលាកាតូលិកនានា។ថ្ងៃនេះ យើងបានស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ "**អ្នករាល់គ្នាជាគង្វាលដែលបោះបង់ហ្វូងចៀមរបស់យើង ឱ្យគេខ្ចាត់ខ្ចាយមុខជាត្រូវវេទនាពុំខាន អ្នករាល់គ្នាបានបោះបង់ចោលកូនចៀមរបស់យើងឱ្យខ្ចាត់ខ្ចាយ ហើយអ្នករាល់គ្នាមិនបានយកចិត្តទុកដាក់នឹងពួកគេទេ**"។ ឱ្យយើងមានកម្លាំង កុំឱ្យយើងចូលនៅក្នុងការស្តីបន្ទោសពីព្រះជាម្ចាស់សម្រាប់យើងផ្ទាល់ ផ្ទុយទៅវិញឱ្យយើងដឹងថាយើងត្រូវការយកចិត្តទុកដាក់។ ដូចព្រះជាម្ចាស់ផ្ទាល់ដែលមានព្រះបន្ទូលថា "**ឥឡូវនេះយើងយកចិត្តទុកដាក់នឹងអ្នករាល់គ្នា គឺដាក់ទោសតាមអំពើអាក្រក់ដែលអ្នករាល់គ្នាបានប្រព្រឹត្ត និងយើងយកចិត្តទុកដាក់ប្រមូលកូនចៀមរបស់យើងដែលនៅសេសសល់ពីគ្រប់ស្រុកដែលយើងបានកំចាត់កំចាយទៅនោះឱ្យត្រឡប់មកវិញ**"។

បងប្អូនជាទីស្រឡាញ់ ជួនកាលយើងមានអារម្មណ៍ថាអស់កម្លាំងដោយសារ ពីប៉ុន្មានខែកន្លងមក យើងផ្សាយទាំងអភិបូជា ទាំងអធិដ្ឋាន ទាំងប្រជុំពីចម្ងាយ ទាំងបង្រៀនពីចម្ងាយ...។ ដូចជាយើង

រកមិនឃើញពេលវេលាដើម្បីសម្រាក យើងរកមិនឃើញពេលវេលាដើម្បីបន្ធូរអារម្មណ៍ យើងរកមិនឃើញពេលវេលាដើម្បីបង្កើតទំនាក់ទំនងសារជាថ្មី។ ផ្ទុយទៅវិញ ពេលយើងស្តាប់ពីមួយថ្ងៃទៅមួយថ្ងៃយើងចង់ភ័យខ្លាចថែមទៀត។ ប៉ុន្តែ យើងដឹងថាព្រះយេស៊ូបានណែនាំឱ្យយើងតស៊ូ យើងដឹងថានឹមរបស់យើងដូចជាស្រាលដោយសារព្រះយេស៊ូផ្ទាល់។ បន្ទុកដែលយើងទទួលពីព្រះយេស៊ូក៏មិនធ្ងន់ដែរ ដោយសារព្រះយេស៊ូគង់នៅ ព្រះយេស៊ូជាម្ចាស់នៃសន្តិភាព។ ព្រះយេស៊ូណែនាំឱ្យយើងទៅមុខពីមួយថ្ងៃទៅមួយថ្ងៃ ដោយយកចិត្តទុកដាក់ថែរក្សាបងប្អូនឯទៀតៗតាមតួនាទីផ្ទាល់ខ្លួន។ ដោយយកចិត្តទុកដាក់ ណែនាំឱ្យមនុស្សយើងរកឃើញសុខសន្តិភាព និងសុភមង្គលដែលហៀរចេញពីព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់។

ថ្ងៃនេះ តាមពិតយើងពោរពេញដោយសេចក្តីសង្ឃឹមសារជាថ្មី យើងពោរពេញដោយកម្លាំងសារជាថ្មី យើងត្រៀមខ្លួនដើម្បីធ្វើរបាយការណ៍ទៅព្រះយេស៊ូអំពីកិច្ចការរបស់យើង។ យើងត្រៀមខ្លួនដើម្បីយកចិត្តទុកដាក់ដល់បងប្អូនរបស់យើងដែលកំពុងអស់កម្លាំង យើងត្រៀមខ្លួនដើម្បីរកឃើញកម្លាំងនៅក្នុងជីវិតរបស់យើងផ្ទាល់។ ជាអ្នកដឹកនាំ ដើម្បីបន្តធ្វើតាមកាលៈទេសៈដោយដឹងថាយើងយកចិត្តទុកដាក់អស់ពីសមត្ថភាព ដើម្បីប្រកាសអំពីសុខសន្តិភាព។ ថ្ងៃនេះទំនុកតម្កើងលេខ២៣ ណែនាំឱ្យយើងពោរពេញដោយសេចក្តីសុខ ដូច្នេះមុនចូលដេកយប់នេះសូមមើលទំនុកតម្កើងនេះម្តងទៀត។ ដោយសារ នេះជាកម្លាំងរបស់ព្រះជាម្ចាស់ដែលប្រទានមកយើង "**ឱព្រះអម្ចាស់ជាគង្វាល មើលឥតរយាលណែនាំខ្ញុំ ឱ្យដើរតាមផ្លូវដែលសាកសម ភោគផលជិតជុំឥតខ្វះឡើយ ព្រះអង្គប្រទានសុភមង្គល ហឫទ័យខ្វាយខ្វល់ដោយអាសូរ មកទូលបង្គំជាហៃហូរ ឥតមានឈប់ឈរមួយជីវិត ដរាបណាជីវិតនៅមាន ខ្ញុំរស់សុខសាន្តឥតមានគិត ក្នុងព្រះដំណាក់ល្អប្រណិត ព្រះអម្ចាស់ស្ថិតស្ថេរជានិច្ច**"។ អាម៉ែន៕

+ លោកអភិបាល អូលីវីយេ ជ្មីតហាស្លេ
អភិបាលព្រះសហគមន៍កាតូលិកកម្ពុជា
ភូមិភាគភ្នំពេញ